Theology on the Web.org.uk
Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

សំណុំនិគឃ្មុំ ២/២ (មេសា ២០០១)៖ ១០១-១០៩



# ជួបជាមួយ លោកគ្រូ គ្រីស្ទហ្វ័រ ឡាប៉ែល

ដោយ លោក អ៊ួន សិលា

គ្រីស្ទហ្វ័រ ឡាប៉ែល

គ្រីស្ទហ្វ័រ ឡាប៉ែល កើតនៅក្នុងគ្រួសារដែលទទួលនូវការអប់រំជ្រៅជ្រះក្នុងទីក្រុង ។ ឪពុករបស់គាត់ធ្វើការនៅក្នុងបរមរាជវាំង ។ គ្រួសារនោះមានកូន ៦ នាក់ គឺ ស្រី ២ និង ប្រុស ៤ នាក់ ។ គ្រីស្ទហ្វ័រគឺជាកូនពៅ នៅក្នុងគ្រួសារនោះ ។

*សំណួរ* : *នៅក្នុងសម័យខ្មែរក្រហម តើគេជម្លៀសលោក ចេញពីភ្នំពេញទៅនៅឯណា?*

ចម្លើយ : តាមដែលខ្ញុំចាំបាន គេបានជម្លៀសយើងចេញពី ភ្នំពេញនៅថ្ងៃទី ១៧ មេសា ឆ្នាំ១៩៧៥ ទៅស្រុកកៀនស្វាយ ភូមិកោះផុស ខេត្តកណ្តាល ។ យើងស្នាក់នៅទីនោះអស់រយៈពេល ៤ ទៅ ៥ ខែ ។ យើងបានជួបមនុស្សខ្លះ ដែលយើងធ្លាប់ស្គាល់ គេធ្វើការជាមួយពួកខ្មែរក្រហមនៅទីនោះ ។ គ្រួសាររបស់យើងមានសេចក្តីភ័យខ្លាចគេសម្លាប់ ក៏សម្រេចចិត្តលួចរត់នៅពេលយប់មួយ ចេញភូមិកោះផុសនោះ តាមកាណូតធ្វើដំណើរឆ្ពោះទៅខេត្តកំពង់ឆ្នាំង ។ យើងទៅដល់កំពង់ឆ្នាំង ក៏ស្នាក់នៅទីនោះរយៈពេលមួយខែ ។ នៅ

ពេលដែល យើងអស់ស្បៀងអាហារ យើងសម្រេចចិត្ត ធ្វើដំណើរឆ្ពោះទៅខេត្តពោធិ៍សាត់ ។ នៅទីនោះ យើង ជួបប្រទះនូវការធ្វើទុក្ខបុកម្នេញ និង ការបំភិតបំភ័យ ដូច្នេះ យើងក៏រត់គេចខ្លួនទៅខេត្តបាត់ដំបង ។ នៅទី នោះបានមួយអាទិត្យ ក្នុងស្រុកស្វាយស៊ីស្ទុផុន ពួកខ្មែរ ក្រហមបានជន្លៀស យើងទៅកាន់ភូមិស្ពួល ស្រុក ព្រះនេត្រព្រះ តំបន់ ៥ ។ យើងលែងបានរស់នៅជួបជុំ គ្នាជាមួយគ្រួសារទៀតហើយ ។ ពួកខ្មែរក្រហមបាន បញ្ជូនយើង ទៅកាន់កងចល័តផ្សេងៗ តាមអាយុរបស់ យើងរៀងៗខ្លួន ។ យើងព្យាយាមលាក់ប្រវត្តិរូបរបស់ យើង ។ នៅពេលដែលខ្មែរក្រហមសួរយើង យើងបាន ប្រាប់គេថា យើងជាអ្នកស្រែចំការសាមញ្ញ ដែលរស់នៅ ក្នុងភូមិ កោះផុស ស្រុកកៀនស្វាយ ចេះតែឆ្លើយៗ អ៊ីចឹងទៅ ។

ខ្ញុំបានសួរគាត់ថា តើគាត់រស់នៅជួបជុំឪពុកម្ដាយ បងប្អូននៅពេល ដែលគាត់ទៅដល់ភូមិស្ពួលមុនដំបូង ។ គាត់បាននិយាយថា៖ "ឪពុក ម្ដាយ បងប្អូនរបស់ខ្ញុំរស់នៅទីនោះរយៈពេលមួយឆ្នាំ ។ ទោះជាយ៉ាងណា ក៏ដោយ ពេលនោះខ្មែរក្រហមបានដឹងថា គ្រួសាររបស់យើងមិនមែនជា កសិករសាមញ្ញនោះឡើយ តែជាអ្នកនៅក្នុងទីក្រុង ពួកគេបានបង្ខំឲ្យ យើងធ្វើការយ៉ាងលំបាកខ្លាំងក្លាមែនទែន ។ ឪពុករបស់ខ្ញុំបានស្លាប់នៅ ក្រោមកណ្ដាប់ដៃពួកខ្មែរក្រហម ដោយការដែលគេបង្ខំឲ្យធ្វើការហួស កម្លាំង នៅដើមឆ្នាំ ១៩៧៦ ពួកគេបានសម្លាប់បងស្រីខ្ញុំនៅចុងឆ្នាំ ១៩៧៦ និង ម្ដាយរបស់ខ្ញុំស្លាប់នៅក្នុងអំឡុងប្រហែលជាដើមឆ្នាំ ១៩៧៧ ។ បង ប្រុសទី៥របស់ខ្ញុំ គេបានយកទៅវៃចោល(ពាក្យនេះគេប្រើក្នុងសម័យ នោះ) នៅក្នុងពេលមួយខែ ក្រោយពេលវៀតណាមចូលស្រុកប៉ុណ្ណោះ ។

នៅក្នុងពេលចូលឆ្នាំចិន នៅក្នុងខែកុម្ភៈ ១៩៧៩ ខ្ញុំបានរត់ចេញពីប្រទេសខ្មែរទៅប្រទេសថៃ ដោយដើរជាមួយអ្នករត់ពន្ធ ហើយខ្ញុំបានស្នាក់នៅក្នុងភូមិថៃ-លាវមួយឈ្មោះថា ភូមិ ណងឯក (គឺជាភូមិថៃ នៅតាមបណ្តោយព្រំប្រទល់ខ្មែរ-ថៃ) នៅជិតស្រុកអារញ្ញ ។ ខ្ញុំចាប់ផ្តើមលក់ថ្នាំពេទ្យ ដល់ជនភៀសខ្លួនខ្មែរ នៅក្នុងជំរុំ ណងចាន់ ។ ពេលដំបូងខ្ញុំបានទៅរកបងប្អូន ក្មួយស្រី ក្មួយប្រុសរបស់ខ្ញុំនៅក្នុងជំរុំ ណងចាន់ ខ្ញុំបានប្រទះឃើញជនភៀសខ្លួន អ្នកខ្លះមានជម្ងឺគ្រុនចាញ់ និង ខ្លះទៀតមានជម្ងឺរាកមួល ។ ពេលដំបូងខ្ញុំគ្រាន់តែចង់ជួយទិញថ្នាំឲ្យគេ ។ ខ្ញុំគ្មានគំនិតអ្វីនឹងរកស៊ីចង់មានចង់បានអីទេពេលនោះ ។ ខ្ញុំមានអំណរអរណាស់ពេលនោះដោយបានរត់គេចរួច ទៅរស់នៅជាមួយខ្មែរ-ថៃ-លាវ បងប្អូនដែលខ្ញុំរស់នៅជាមួយនោះ គេល្អចំពោះខ្ញុំណាស់ ។ មុខរបរជួញដូរថ្នាំពេទ្យ (ទិញថ្នាំឲ្យគេ បងប្អូនខ្មែរដូរមាសមកវិញ) ក៏ចាប់ផ្តើមរីកចំរើន ប៉ុន្តែការរកស៊ីរត់ពន្ធឆ្លងកាត់ព្រំប្រទល់នោះ គឺជារបរខុសច្បាប់ ។ ជួនកាលក៏ចំណេញ ជួនកាលក៏ខាតហើយជួនកាលក៏ត្រូវទាហានថៃចាប់ ។ សេចក្តីភ័យខ្លាចគេសម្លាប់នៅក្នុងអារម្មណ៍របស់ខ្ញុំជានិច្ច ។ ជួនកាល ខ្ញុំក៏ចេញទៅដូរថ្នាំពេទ្យជាមួយជនភៀសខ្លួនខ្មែរ ហើយពេលខ្លះ ក៏ដេកនៅកន្លែងស្នាក់នៅនោះ ។

ថ្ងៃមួយខ្ញុំបានឃើញ ក្បួនឡានដឹកជនភៀសខ្លួនខ្មែរចេញពីជំរុំតាមព្រំប្រទល់ដែន ទៅក្នុងជំរុំ ខៅអ៊ីដាង ។ ខ្ញុំនឹកដល់បងប្អូនសាច់ញាតិរបស់ខ្ញុំ ចំណែកខ្ញុំបានរស់នៅក្នុងកន្លែង ដែលមានសុវត្ថិភាព ខ្ញុំក៏បានព្យាយាមធ្វើដំណើរទៅជំរុំ ខៅអ៊ីដាង ដើម្បីស្វែងរកបងប្អូនសាច់ញាតិរបស់ខ្ញុំ ដែលនៅសល់ពីស្លាប់ ។ ខ្ញុំរកមិនឃើញសាច់ញាតិណាម្នាក់សោះ នៅក្នុងជំរុំ ខៅអ៊ីដាង ប៉ុន្តែខ្ញុំបានជួបជាមួយមិត្តភក្តិខ្ញុំម្នាក់ ដែលរៀននៅក្នុងសាលាជាមួយគ្នា ។ គាត់បានបបួលខ្ញុំឲ្យមកស្នាក់នៅជាមួយគាត់ ។ ខ្ញុំក៏យល់ព្រមរើមករស់នៅក្នុងជំរុំ ជាមួយគាត់ ស្ថិតក្រោមការ

មើលថែរបស់អង្គការ UNHCR ហើយពេលនោះខ្ញុំសម្រេចចិត្តឈប់រកស៊ីរត់ពន្ធទៀតហើយ ។

នៅថ្ងៃដំបូង ដែលខ្ញុំបានទៅដល់ជំរុំ ខៅអ៊ីដាង គឺជាថ្ងៃដែលខ្ញុំបានឮដំណឹងល្អ តាមរយៈបេសកជនមកពីបស្ចិមប្រទេស ។ គេបានប្រាប់ខ្ញុំពីព្រះយេស៊ូគ្រីស្ទ ។ ព្រះយេស៊ូ គឺជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ។ ព្រះអង្គសុគតនៅលើឈើឆ្កាងជំនួសបាបយើង ។ ដំណឹងល្អនោះ ធ្វើឲ្យខ្ញុំរំភើបចិត្តយ៉ាងខ្លាំង គឺធ្វើឲ្យខ្ញុំនឹកឃើញដល់វ័យកុមារភាពរបស់ខ្ញុំ ។ ខ្ញុំចូលចិត្តឈើឆ្កាងខ្លាំងណាស់ ។ មានអ៊ុំម្នាក់ជាជាងចម្លាក់ ដែលធ្វើការនៅក្នុងបរមរាជវាំង បានឲ្យឈើឆ្កាងធ្វើអំពីភ្លុកមួយមកឲ្យខ្ញុំ ។ ខ្ញុំមិនបានដឹងថា ឈើឆ្កាងនោះជាស្អីទេ ខ្ញុំគ្រាន់តែដឹងថាខ្ញុំស្រឡាញ់ឈើឆ្កាងនោះខ្លាំងណាស់ គឺខ្ញុំពាក់ជាប់នឹងករបស់ខ្ញុំគ្រប់ពេល ។ ខ្ញុំស្រឡាញ់ឈើឆ្កាងនោះស្រឡាញ់មែនទែន ។ ឪពុករបស់ខ្ញុំមិនចូលចិត្ត ដោយឃើញខ្ញុំពាក់ឈើឆ្កាងនោះឡើយ ។ គាត់បានហៅខ្ញុំថា អាកាតូលិក ។ នៅពេលបាយ ឬនៅពេលស្ថិតនៅចំពោះមុខឪពុករបស់ខ្ញុំ ខ្ញុំតែងតែបង្វិលឈើឆ្កាងនោះដាក់ទៅខាងក្រោយវិញ ។

ខ្ញុំនៅចាំបានម្តង ឬ ពីរដងកាលពីសម័យប៉ុល ពត នៅក្នុងភូមិស្ពួល ខ្ញុំបានទៅច្រូតស្បូវមកប្រក់ដំបូលរោង ពេលនោះខ្ញុំ មានជម្ងឺគ្រុនក្តៅយ៉ាងខ្លាំង ។ ដូចលោកជ្រាបហើយថា ក្នុងសម័យ ប៉ុល ពត បើសិនជាយើងខានធ្វើការបួនប្រាំថ្ងៃ គេគិតថាយើងព្យាយាមគេចវេះពីការងារ ។

ពួកទាហានខ្មែរក្រហម គេបានហៅខ្ញុំទៅសួរ ដើម្បីឲ្យដឹងច្បាស់ថាខ្ញុំពិតជាឈឺពិតមែនឬទេ បើពុំនោះទេ គេនឹងសម្លាប់ខ្ញុំ ។ ពួកគេបានសួរខ្ញុំថា "មិត្តឯងពិតជាឈឺមែន ឬក៏ឈឺពុតដោយខ្ជិលទៅធ្វើការ?" ខ្ញុំបានឆ្លើយថា "ខ្ញុំគ្រុនបួនប្រាំថ្ងៃហើយមិត្តបង" (ពាក្យនេះគេប្រើនៅក្នុងជំនាន់ប៉ុល ពត) ។ យើងដឹងហើយថា នៅពេលដែលពួកខ្មែរក្រហមហៅយើង ជាពិសេសនៅពេលយប់គឺមានន័យថា យើងប្រាកដជាស្លាប់

ហើយ ។ នៅពេលនោះ មានដៃជាច្រើនមកស្ទាប ដើម្បីស្ទង់កម្ដៅនៅលើខ្លួនខ្ញុំ ។ ដៃខ្លះស្ទាបថ្ងាស ដៃខ្លះស្ទាបមុខរបស់ខ្ញុំ ។ នៅកណ្ដាលយប់ងងឹតឈឹង ខ្ញុំមិនដឹងថាជាដៃនរណាខ្លះឡើយ ដែលគេស្ទាបខ្ញុំ ។ ខ្ញុំគ្រាន់តែដឹងថា ពេលនោះមានដៃមួយ ហែកអាវរបស់ខ្ញុំ ហើយស្ទាបដើមទ្រូងរបស់ខ្ញុំ ក៏ស្ទាបប៉ះចំឈើឆ្កាង ។ ក្រោយមកខ្ញុំ ឮសូរសម្លេងនិយាយថា: "គាត់ពិត ជាឈឺមែនហើយ ។ ចូរមើលឲ្យចំណីចំណុក និង ឲ្យគាត់សម្រាកឲ្យបានស្រួលបួលផង មិនបាច់ដកចេញទេ" (កាលពីសម័យនោះគេប្រើពាក្យទុកមិនចំណេញ ដកចេញមិនខាត ពាក្យដកចេញ គឺមានន័យថា សម្លាប់ចោល) ។

នៅពេលដែលខ្ញុំដើរត្រឡប់មកកន្លែងរោងស្នាក់នៅវិញ ខ្ញុំឆ្ងល់ថា យ៉ាងម៉េចបានជាឈើឆ្កាងនេះអាចជួយខ្ញុំ ឲ្យរួចជីវិតពីកណ្ដាប់ដៃពួកខ្មែរក្រហម ។ ពួកខ្មែរក្រហមបានបញ្ជូនខ្ញុំទៅកាន់មន្ទីរពេទ្យមួយ ។ ខ្ញុំក៏សន្លប់បាត់ស្មារតី លែងដឹងខ្លួន ហើយខ្ញុំក៏មិនដឹងថា ឈើឆ្កាងធ្វើអំពីភ្លុកនោះជ្រុះបាត់នៅកន្លែងណាដែរ ។ កាលពីពេលនោះ ខ្ញុំពិតជាមិនដឹងថាតើឈើឆ្កាងនោះ មានន័យយ៉ាងណាដែរ ។ កាលខ្ញុំឈឺនោះ គេបានបញ្ជូនខ្ញុំទៅកាន់មន្ទីរពេទ្យស្វាយស៊ីសូផុន តែខ្ញុំមិនដឹងថា ឈើឆ្កាងនោះបាត់នៅកន្លែងណាទេ ។

ខ្ញុំឆ្ងល់ថា តើឈើឆ្កាងនេះជាអ្វីទៅហ្ន៎ ! នៅពេលខ្ញុំទៅដល់ខៅអ៊ីដាង ពេលនោះខ្ញុំបានឮដំណឹងល្អ ខ្ញុំចាប់ផ្ដើមដឹងភ្លាមថា ព្រះយេស៊ូជាព្រះអង្គសង្គ្រោះ ។ ដូច្នេះខ្ញុំបានសម្រេចចិត្តដើរតាមព្រះយេស៊ូភ្លាមនៅពេលនោះឯង ។ នៅពេលដែលខ្ញុំអធិស្ឋានយាងព្រះអង្គមកគង់ក្នុងចិត្តរបស់ខ្ញុំ ខ្ញុំបានផ្លាស់ប្រែភ្លាម ។ គឺដោយសារតែអំណាចចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ សេចក្ដីសម្អប់ជាប់ក្នុងគំនុំសងសឹកចង់សម្លាប់ អ្នកដែលបានសម្លាប់បងប្អូន ក្រុមគ្រួសាររបស់ខ្ញុំ ស្រាប់តែរលាយបាត់ពីក្នុងចិត្តរបស់ខ្ញុំ ដោយសេចក្ដីស្រឡាញ់ សេចក្ដីអំណរ និង សេចក្ដីសុខសាន្ត

ព្រមទាំងបាត់អស់ នូវសេចក្ដីភ័យខ្លាច ។ ខ្ញុំមានសេចក្ដីមេត្តាករុណា ចំពោះជនរួមជាតិរបស់ខ្ញុំ ។ គឺធ្វើឲ្យខ្ញុំចង់បំរើដល់ប្រជាជាតិរបស់ខ្ញុំ ។ ជាពិសេសខ្ញុំចង់ចែករំលែកនូវបទពិសោធន៍ ដែលខ្ញុំមានជាមួយព្រះជាម្ចាស់ ដល់មិត្តភក្ដិ និង បងប្អូនរបស់ខ្ញុំ ។

*សំណួរ* : *តើលោកទៅសហរដ្ឋអាមេរិកពីឆ្នាំណា?*

ចម្លើយ : ខ្ញុំស្នាក់នៅជំរំ ខៅអ៊ីដាង ប្រហែល ៦ ខែ ។ ខ្ញុំបានរៀបការ រួចបានមួយអាទិត្យ ។ ប្រពន្ធរបស់ខ្ញុំក៏ជាគ្រីស្ទបរិស័ទដូចខ្ញុំដែរ ។ ស្រាប់តែមានមនុស្សម្នាក់ធ្វើការនៅស្ថានទូតដើររកឈ្មោះខ្ញុំ ។ គាត់នោះប្រាប់ខ្ញុំថា ខ្ញុំមានឈ្មោះទៅអាមេរិក ខ្ញុំស្ទើរតែមិនជឿត្រចៀករបស់ខ្ញុំ ។ ក្រុមរបស់ខ្ញុំគឺជាក្រុមដំបូងគេ ដែលបានធ្វើដំណើរចេញពីជំរុំ ខៅអ៊ីដាង ទៅកាន់ប្រទេសទីបី ។ ខ្ញុំចាកចេញពី ខៅអ៊ីដាង នៅក្នុងខែមិថុនា ឆ្នាំ ១៩៨០ ។ ដំបូងខ្ញុំស្នាក់នៅក្នុងជំរុំ ឈុនបូរី អស់រយៈពេលពីរបីអាទិត្យ បន្ទាប់មកទៅបាងកក ហើយនៅពេលចុងក្រោយ យើងស្នាក់នៅក្នុងប្រទេសភីលីពីន អស់រយៈពេល ៥ ខែ ។ នៅពេលដែលយើងនៅទីនោះ យើងបានថ្វាយបង្គំព្រះជាមួយបងប្អូនគ្រីស្ទបរិស័ទ នៅក្នុងប្រទេស ភីលីពីន ។ យើងចង់បំរើដល់បងប្អូនខ្មែរ នៅទីនោះ ពីព្រោះយើងចេះភាសាអង់គ្លេស ហើយនិងយើងចង់ហាត់និយាយភាសា ដោយការព្រមធ្វើការជាមួយអង្គការមនុស្សធម៌អន្តរជាតិ ។ អរព្រះគុណព្រះ ដែលខ្ញុំមានឱកាសបានធ្វើការជាមួយអង្គការ **"Christian Outreach"** កាលនៅជំរុំ ខៅអ៊ីដាង ។ យើងបានទទួលនូវការហ្វឹកហ្វឺនឲ្យយល់ពីព្រះបន្ទូល និង មានការរីកចំរើនក្នុងទំនាក់ទំនង

ជាមួយព្រះជាម្ចាស់ តាមរយៈការធ្វើការងារជាមួយ អង្គការគ្រីស្តបរិស័ទ ។ ពួកគេបានបញ្ជូនយើងពីជំរុំមួយទៅជំរុំមួយទៀត ដូច្នេះយើងអាចរៀន ពីច្បាប់ទម្លាប់ផ្សេងៗ ។

*សំណួរ* : *បន្ទាប់ពីលោករស់នៅ សហរដ្ឋអាមេរិក តើរយៈពេលប៉ុន្មានឆ្នាំ មុនពេលលោកចាប់ផ្តើមបំរើព្រះជាម្ចាស់?*

ចម្លើយ : ខ្ញុំរស់នៅសហរដ្ឋអាមេរិក អស់រយៈពេល ៩ ឆ្នាំ មុនត្រឡប់មកបំរើព្រះអម្ចាស់ នៅក្នុងប្រទេសកម្ពុជា នៅក្នុងខែកក្កដា ឆ្នាំ ១៩៨៩ ការងារបំរើព្រះដំបូងរបស់ខ្ញុំ គឺបំរើព្រះជាមួយបងប្អូនជនភៀសខ្លួន នៅក្នុងជំរុំ **Site 2** និង **Site B** ។ ខ្ញុំបានបង្កើតព្រះវិហារពីរកន្លែង នៅក្នុងជំរុំ **Site B** ក្នុងឆ្នាំ ១៩៩១ ។ ខ្ញុំបានស្នើទៅអង្គការ **UNBRO** ឲ្យធ្វើមាតុភូមិនិវត្តន៍ ប្រហែល ១៥០ គ្រួសារនៃបងប្អូនគ្រីស្តបរិស័ទយើង ត្រឡប់ចូលមកស្រុកខ្មែរជាក្រុម ។ ទោះបីគេបញ្ជូនទៅទីណាក៏ដោយ សូមឲ្យគេបញ្ជូនជាក្រុមៗ ។ គេក៏បានសម្រេចតាមសំណើរបស់ខ្ញុំ គេក៏បញ្ជូនបងប្អូនយើងទៅកាន់ចំការសំរោង ខេត្តបាត់ដំបង ។ ខ្ញុំបានចុះមកស្រុកខ្មែរ ជាអ្នកបង្កើតពួកជំនុំ ។

*សំណួរ* : *តើលោកមកពីក្រុមជំនុំណាទៅ?*

ចម្លើយ : ក្រុមជំនុំរបស់ខ្ញុំ ជាក្រុមជំនុំឯករាជ្យ គឺគ្មាននិកាយឡើយ ។ ខ្ញុំចូលចិត្តធ្វើការរួមជាមួយបងប្អូនគ្រីស្តបរិស័ទ ដោយមិនប្រកាន់និកាយអ្វីឡើយ ។ ប៉ុន្តែចំពោះពួកខុសឆ្គង ខ្ញុំមិនអាចរួមជាមួយបានឡើយ ។

*សំណួរ* : *នៅពេលចុងបញ្ចប់នេះ ខ្ញុំសុំសួរលោកថា តើលោកមានសំណូមពរអ្វី ដើម្បីចង់ស្នើឡើង? តើលោកចង់ឲ្យបង*

*ប្អូនគ្រីស្តបរិស័ទ អធិស្ឋានឲ្យលោកដោយរបៀបណា? ហើយសូមចែករំលែកពត៌មានបន្តិចបន្តួចពីរឿងលោក ឌុច ផងបានទេ?*

ចម្លើយ : ខ្ញុំចង់សម្តែងនូវដួងចិត្ត ដ៏ស្មោះស្ម័គ្ររបស់ខ្ញុំ ដល់បងប្អូនប្រុសស្រីរួមជំនឿជាមួយព្រះគ្រីស្ត ។ សូមឲ្យបងប្អូនស្រឡាញ់គ្នា ដូចព្រះគ្រីស្តស្រឡាញ់យើង និង បង្គាប់ឲ្យយើងស្រឡាញ់គ្នា ។ ការស្រឡាញ់គ្នាបង្ហាញឲ្យដឹងថាយើងស្រឡាញ់ព្រះយេស៊ូ ។ បងប្អូនខ្មែរជាអ្នកបំរើព្រះនៅទីនេះ ពិសេសណាស់សម្រាប់ខ្ញុំ ។ ខ្ញុំសូមលើកតម្លៃបងប្អូនបំរើព្រះនៅទីនេះ ខ្ពស់ដោយការខិតខំទ្រាំទ្រការលំបាកគ្រប់បែបយ៉ាង ដោយសារការបំរើព្រះ ។ ក្នុងនាមខ្ញុំ ជាបេសកជនបំរើព្រះ នៅសហរដ្ឋ ខ្ញុំសូមសម្តែងនូវការអរគុណយ៉ាងជ្រាលជ្រៅ ដែលបងប្អូនបានឲ្យខ្ញុំបំរើព្រះជាមួយគ្នា ។ សូមឲ្យបងប្អូនបានរាប់ខ្ញុំជាខ្មែរម្នាក់ផង ! ដោយខ្ញុំជាខ្មែរ មានឈាមជ័រជាខ្មែរ កើតមកជាខ្មែរ នៅ ::លើទឹកដីខ្មែរ ទោះបីខ្ញុំនៅស្រុកក្រៅក៏បញ្ញាចិត្តខ្ញុំក៏នៅតែជាខ្មែរ ស្រឡាញ់ខ្មែរ ហើយនិងចង់ឲ្យបងប្អូនខ្មែរ ស្គាល់ព្រះយេស៊ូ ស្គាល់ពីសេចក្តីពិត ហើយឲ្យគេបានស្គាល់ពីការពិសោធន៍ នៅក្នុងជីវិតរបស់គេ ជាមួយព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ ! ។

ខ្ញុំមានអំណរ ដោយឃើញបងប្អូន មានចិត្តរួបរួមគ្នា ដូច្នេះសូមឲ្យយើងបន្ត ការស្រឡាញ់រួបរួមគ្នា និង បំរើព្រះជាមួយគ្នា ប្រយោជន៍ឲ្យយើងនាំព្រលឹងជនជាតិខ្មែរថ្វាយព្រះយេស៊ូ ! ។

នៅពេលដែល ខ្ញុំបានជួប ឌុច មុនដំបូង ខ្ញុំមិនដឹងថា គាត់ជាអតីតខ្មែរក្រហមនោះឡើយ ។ គាត់ជាមនុស្ស សង្ហាតខំរៀន ។ នៅពេលធ្វើសិក្ខាសាលា គាត់សួរ សំណួរជាច្រើន ។ បន្ទាប់ពីសិក្ខាសាលា រយៈពេលបួន ប្រាំថ្ងៃ គាត់សម្រេចចិត្តថ្វាយខ្លួនជឿដល់ព្រះជាម្ចាស់ និង ព្រមទទួលពិធីជ្រមុជទឹក ។ ជីវិតរបស់គាត់ប្តូរផ្លាស់ ទាំងស្រុង ។ គាត់បានវិលត្រឡប់មកភូមិរបស់គាត់វិញ និង នាំបងប្អូនគាត់មួយចំនួន ឲ្យទទួលជឿព្រះអម្ចាស់ គាត់បានដឹកនាំក្រុមជំនុំ នៅតាមផ្ទះនៅក្នុងតំបន់គាត់រស់ នៅនោះ ។ គាត់និយាយថា គាត់មិនខ្លាចនឹងនិយាយ ពីសេចក្តីពិតឡើយ ។ រឿងវាកើតឡើងដូច្នេះឯង ។ ខ្ញុំ គ្មានអំណាចអ្វី ដើម្បីបង្ខំនាំឲ្យគាត់ព្រមសារភាពនោះ ឡើយ ប៉ុន្តែព្រះជាម្ចាស់ ព្រះអង្គមាន អំណាចចេស្តា និង សេចក្តីមេត្តាករុណាដ៏លើសលប់ គឺព្រះអង្គអាច បំផ្លាស់បំប្រែដួងចិត្តបានទាំងស្រុង ។

HONEYCOMB 2/2 (April 2001): 110–115



# Meet Christopher LaPel

*UON Seila*

*Christopher LaPel*

Christopher LaPel was born to a well-educated city family. His father worked in the Royal Palace. The family had six children—two girls and four boys. Christopher was the smallest member of his family.

**Q:** During the Khmer Rough era, where did you go when you were evacuated from Phnom Penh?

**A:** So far as I remember we were evacuated from Phnom Penh April 17, 1975, to Kien Svay district, Koh Phos village, Kandal province. We stayed there for several months. We met some people whom we knew were working with the Khmer Rouge. Our family felt afraid of being killed, so one night we escaped from that village by motorboat to Kampong Chhnang. We stayed there one month. When we ran out of our food supplies we decided to move to Pursat province. There we faced further persecution and intimidation, so we escaped to Battambang by train. After one week in Svay Sisophon the Khmer Rouge evacuated us to Snoul, Preahnet Preah district region 5. We no longer lived together as family. The Khmer Rouge sent us to

> different hard labor mobile groups according to our ages. We tried to hide our identities. When the Khmer Rouge questioned us we told them we were just simple peasants who lived in Koh Phos village, Kien Svay district and so on.

I asked him if his family were still alive when first he arrived in Snoul district. He replied, "My family survived for nearly one year. However, when the Khmer Rouge discovered that we were not farmers but city people they forced us to work at extremely hard labor. My father died in early 1976 because of this hard labor. They killed my sister in late 1976 and my mother around early 1977. My fifth brother was butchered only one month after the Vietnamese came into the country.

"During Chinese New Year in February 1979 I escaped from Cambodia to Thailand by foot and stayed in a Thai-Laotian village called Nong Ek (one of Thai villages along the Cambodia-Thailand border) near Aranyaprathet. I started a business selling medicine to the Cambodian refugees in Nong Chan Camp. When I went to visit Nong Chan Camp to look for my sister, brother, nieces, and nephews, I encountered some refugees who had malaria and dysentery. At first I only wanted to help them buy medicine. My intention was not to do business for riches. I was so happy that I could escape to live with Khmer-Thai-Laotian people. The people with whom I lived had been good to me. My business of bartering medicine for gold started to grow, but this business of smuggling things across the border was illegal. The business went up and down, and sometimes I was caught by Thai soldiers.

"The fear of being killed still buzzed around me. Sometimes I went to barter medicine with Cambodian refugees; other times I slept in.

"One day I saw a convoy of buses carrying Cambodian refugees from the camp along the border into Kao I Dang Camp. I missed my relatives while I lived in a safe place so I tried to go to Kao I Dang to trace any relatives who had survived the killing fields. In the Kao I Dang Camp (KID) I could not find anyone of my relatives, but I met one of my schoolmates. He urged me to

come and stay with him. I agreed and moved to his camp under the protection of UNHCR, and decided to quit my smuggling business.

"The first day I moved to stay in KID was the day I heard Good News through a missionary from the West. They told me about Jesus Christ. Jesus is the Son of God. He died on the cross for our sin. It stirred my excitement and reminded me of my childhood. I liked the cross very much. One of the sculptors in the royal palace had given me a cross made of ivory. I did not know what it was, but I only knew that I liked it and I wore on my neck all the time. I loved it very much. My father was not glad that I wore the cross. He called me a Catholic. During meals or in front of father I usually turned the cross back to behind my neck.

"I remembered once or twice in the Pol Pot time in Snoul I went to cut grass to make a thatch roof and I got a very high fever. As you know during the Pol Pot time if we were absent from work several days we were considered to be trying to escape from work.

"The Khmer Rouge cadres called and questioned me to make sure I was really sick. If not they would kill me. They asked, 'Are you really sick, or just too lazy to work?' I replied, 'I have had a fever for several days, comrades.' (This is a term we used in the Pol Pot time.) We knew that every time the Khmer Rouge summoned us, especially at night, it meant we would die. I felt many hands palpate me to check my temperature. Some felt my forehead; other hands groped my face. In the dark I could not tell whose hand was touching me. I only knew that one hand tore my shirt, touched my chest, and fondled the cross. Then a voice spoke: 'He is really sick. Let him go back, don't take him away (i.e., don't kill him). Provide him food and let him rest.'

"When I walked back to my resting place I wondered how this cross could have saved me from the hand of the Khmer Rouge. They sent me to a hospital. I was unconscious and I did not know where I lost the ivory cross. During that time I really did not know what the cross meant. When I was sick I was sent to Svay Sisophon Hospital, so I didn't know where I lost my cross.

"I wondered what the cross was. When I came to KID and heard the gospel story I realized immediately that Jesus is the

Savior. So I decided to follow Jesus right then. When I prayed to invite the Lord into my heart I completely changed. That is, by the power of the Holy Spirit my heart's hatred and revengeful desire to kill those who killed my family members completely left. At that moment the Holy Spirit filled my heart with love, joy, and peace, and took away all my fear. And I had a compassion for my compatriots. It made me want to serve my people. I especially wanted to share my experience with God with my friends and relatives."

**Q:** When did you go to the USA?

**A:** I stayed in KID about 6 months. I had been married for only one week. My wife is a Christian, too. There was someone working in the embassy looking for me. He told me that my name was chosen for resettlement in the USA. I could not believe my ears! My group was the first to leave KID for overseas. We departed in June 1980. At first we stayed in a transit camp in Chhun Bori for several weeks, then moved to Bangkok, and finally we stayed in Philippines for five months. While there we worshiped the Lord with our Christian brothers and sisters in Philippines.

We liked to serve the people because we knew English and we wanted to practice it by working with an international organization. Praise God I had the opportunity to work with the NGO "Christian Outreach" back in KID. We were trained to understand God's Word and grow into a good relationship with Him through our working with this Christian NGO. They moved us from one camp to another camp so we could learn different laws and customs.

**Q:** After you came to the United States, how much time elapsed before you began to serve the Lord?

**A:** I lived in the United States nine years before returning to serve the Lord in Cambodia in July 1989. My first service was with refugees in Site 2 and Site B. I planted two churches in Site B camp in 1991.

I requested UNBRO to repatriate about 150 families of our Christian brothers and sisters back into Cambodia in groups. They would go anywhere but wanted to settle in clusters. They agreed to my request, so they brought those people to Chamcar Samrong, Battambang. I came to Cambodia to serve as a church planter.

**Q:** What kind of church are you from?

**A:** My church is an independent church with no denomination. I like to be united with Christian regardless of denomination. But as for cults, I cannot be united with them.

**Q:** At the end of this interview let me ask what kind of request would you like to make? How do you want our Christian brothers and sisters to pray for you? And could you share a little bit about Duch?

**A:** I want to express my heartfelt gratitude to our brothers and sisters in Christ. May you love one another as Christ loves us and commands us to love. Love for one another reflects the love of Jesus. Our brothers and sisters here are exceptionally special for me. I value highly their perseverance in their faith and service to the Lord. As a missionary from overseas I greatly appreciate you guys here allowing me to serve the Lord as your partner. Please receive me as a Cambodian! I have Khmer blood and was born as a Khmer in Khmer territory. Even though I live overseas I still deeply love Cambodia and wish all Khmers know Jesus and experience the truth and love of God in their hearts.

I am very happy to see we have unity, and I urge you to keep loving one another and serve God to win more souls among the Khmer!

When I met Duch the first time I did not realize that he was a former Khmer Rouge. He was an eager learner. He asked a lot of questions during a seminar. After several days of this seminar he decided to give his life to God and got baptized. His life completely changed. He came to his

village and led a number of his relatives to the Lord. He led a home church at his area.

He said he had no fear and he had to speak the truth. So it happened like this. I had no power to lead him to do that, but our God is powerful and merciful. He can change a man's heart completely.